

WFP

World Food Programme

SAVING LIVES

CHANGING LIVES

# បច្ចុប្បន្នភាពនៃការតាមដានរដូវកាលក្នុងប្រទេសកម្ពុជា

គិតត្រឹមថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២

**ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះ (VAM)**

# របាយទឹកភ្លៀង

ទឹកភ្លៀងក្នុងរយៈពេល ៣ខែចុងក្រោយ (ខែវិច្ឆិកា-មករា ឆ្នាំ២០២២) មានកម្រិតច្រើនជាងមធ្យមភាគច្រើនឆ្នាំ នៅភាគខាងត្បូងឈៀងខាងលិចនៃប្រទេស (ផែនទីខាងក្រោម)។ ទោះយ៉ាងណា ទឹកភ្លៀងទទួលបានជាមធ្យមថ្នាក់ជាតិក្នុងខែមករា ឆ្នាំ២០២២ ទាបជាងមធ្យមភាគច្រើនឆ្នាំបន្តិច។

## មធ្យមភាគទឹកភ្លៀងថ្នាក់ជាតិ (គិតត្រឹមខែមករា ឆ្នាំ២០២២) និងប្រតិទិនដំណាំតាមរដូវកាល




| | | | | | |
|---|---|---|---|---|---|
| ស្រូវប្រាំង | ដាំដុះ | ប្រមូលផល | | | រៀបចំដី និង សាបព្រោះ |
| ស្រូវវស្សា | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | ស្ទូង/ដាំដុះ | ប្រមូលផល |

## សន្ទស្សន៍កម្រិតទឹកភ្លៀងស្តង់ដារក្នុងរយៈពេល ៣ខែ (វិច្ឆិកា ២០២១ - មករា ២០២២)




Source: Rainfall from CHIRPS and analysis by WPF

# ស្ថានភាពរុក្ខជាតិ និងដំណាំ

ស្ថានភាពអាកាសធាតុសើមក្នុងខែវិច្ឆិកា-មករា ឆ្នាំ២០២២ បានផ្តល់លក្ខណៈសមប្រកបសម្រាប់រុក្ខជាតិ។ ក្នុងខែមករា រុក្ខជាតិនៅតំបន់ភាគច្រើននៅទូទាំងប្រទេស មានស្ថានភាពចាប់ពីធម្មតារហូតដល់លើសមធ្យមភាគច្រើនឆ្នាំ បើទោះបីរុក្ខជាតិនៅផ្នែកខ្លះនៃខេត្តឧត្តរមានជ័យ សៀមរាប កំពង់ធំ និងក្រចេះ ជួបស្ថានភាពក្រោមមធ្យមភាពច្រើនឆ្នាំ ដែលនេះបង្ហាញសញ្ញាអាចមានរាំងស្ងួត ក៏ដោយ (ផែនទីខាងស្តាំ)។

យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការប្រមូលផលស្រូវរដូវវស្សាបានចំនួន ៩,០៦ លានតោន គឺខ្ពស់ជាងឆ្នាំមុន ១០,២% គិតត្រឹមខែធ្នូ ឆ្នាំ២០២១។ ផ្ទៃដីដាំដុះដំណាំសំខាន់ៗ ក្នុងរដូវប្រាំងគិតត្រឹមខែធ្នូ ឆ្នាំ២០២១ ដែលមានដូចជា៖ ស្រូវបាន ៤៦៧.០៩៨ ហិកតា (ទាបជាងឆ្នាំមុន ៥,៨%) ដំណាំសារប្បកម្មបាន ២០.០៣៣ ហិកតា (ទាបជាងឆ្នាំ១៧,៤%) និងដំណាំឧស្សាហកម្មបាន ៤៨.១៩៦ ហិកតា (ទាបជាងឆ្នាំមុន ៩,៧%)។

បម្រែបម្រួលនៃសន្ទស្សន៍រុក្ខជាតិ ក្នុងខែមករា ២០២២




Source: Vegetation Index from MODIS and analysis by WPF and agriculture information from MAFF’s report released on 06 January 2022

# កម្ពស់ទឹកទន្លេ

យោងតាម គណៈកម្មការទន្លេមេគង្គ (MRC) បានរាយការណ៍ថា នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ កម្ពស់ទឹកទន្លេនៅស្ថានីយ៍ទាំង៨ ក្នុងប្រទេសកម្ពុជា ស្ថិតនៅស្ថានភាពធម្មតា។ តាមការព្យាករណ៍សម្រាប់ ១ សប្តាហ៍ចាប់ពីថ្ងៃទី១៥-២១ ខែកុម្ភៈ កម្ពស់ទឹកទន្លេមេគង្គ ចាប់ពីស្ទឹងត្រែង ដល់ក្រចេះមាននិន្នាការកើនឡើងបន្តិច ប៉ុន្តែចាប់ពីកំពង់ចាម ដល់អ្នកលឿង និងព្រមទាំងកម្ពស់ទឹកទន្លេសាប និងទន្លេបាសាក់នឹងថយចុះបន្តិច។

កម្ពស់ទឹកទន្លេនៅថ្ងៃទី ១៤ ខែកុម្ភៈ និងការព្យាករណ៍ចាប់ពីថ្ងៃ១៥-២១ ខែកុម្ភៈ ឆ្នាំ២០២២

| Location | Observed Rainfall (mm) | Zero gauge above M.S.L (m) | Min WL | Observed W. level againt zero gauge(m) | | Forecasted Water Levels (m) | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| - | 13-02-2022 | - | - | 13-02-2022 | 14-02-2022 | 15-02-2022 | 16-02-2022 | 17-02-2022 | 18-02-2022 | 19-02-2022 | 20-02-2022 | 21-02-2022 |
| Stung Treng | nr | 36.79 | 0.32 | 2.56 | 2.57 | 2.57 | 2.57 | 2.57 | 2.58 | 2.6 | 2.62 | 2.64 |
| Kratie | nr | -1.08 | 3.06 | 7.04 | 7 | 7 | 7.01 | 7.01 | 7.01 | 7.02 | 7.04 | 7.06 |
| Kompong Cham | nr | -0.93 | 0.65 | 2.74 | 2.72 | 2.69 | 2.67 | 2.65 | 2.63 | 2.61 | 2.6 | 2.6 |
| Phnom Penh (Bassac) | nr | -1.02 | 1.58 | 2.29 | 2.23 | 2.21 | 2.18 | 2.16 | 2.14 | 2.12 | 2.1 | 2.09 |
| Phnom Penh Port | - | 0 | 0.14 | 1.31 | 1.25 | 1.23 | 1.2 | 1.18 | 1.16 | 1.14 | 1.12 | 1.11 |
| Koh Khel | nr | -1 | 1.52 | 2.26 | 2.2 | 2.16 | 2.14 | 2.11 | 2.09 | 2.07 | 2.05 | 2.03 |
| Neak Luong | 9.8 | -0.33 | 0.81 | 1.96 | 1.98 | 1.94 | 1.85 | 1.75 | 1.71 | 1.69 | 1.67 | 1.66 |
| Prek Kdam | nr | 0.08 | 0.58 | 1.32 | 1.27 | 1.23 | 1.19 | 1.16 | 1.13 | 1.1 | 1.07 | 1.04 |

MRC Flood Forecasting: http://ffw.mrcmekong.org/ , accessed on 16 Feb 2022

# ការព្យាករណ៍រយៈពេលខ្លី

តាមការចេញផ្សាយរបស់ក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី១៥ ខែកុម្ភៈ ខេត្តជាច្រើនក្នុងប្រទេសកម្ពុជានឹងអាចទទួលទឹកភ្លៀងពីតិច ទៅបង្គួរ លើកលែងតែខេត្តចំនួន ៦ ដូចជាៈ ខេត្តកំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន នឹងអាចមានភ្លៀងច្រើនចាប់ពីថ្ងៃទី១៦-២២ ខែកុម្ភៈ។

ប្រភពដទៃទៀត ក៏បានបញ្ជាក់ផងដែរថា សម្រាប់ការព្យាករណ៍រយៈពេល១សប្តាហ៍ ចាប់ពីថ្ងៃទី១៦-២២ ខែកុម្ភៈ ទឹកភ្លៀងទទួលបាននៅទូទាំងប្រទេសអាចនឹងមានកម្រិតចាប់ពីធម្មតារហូតដល់ច្រើនជាងមធ្យមភាគច្រើនឆ្នាំ (ផែនទីខាងស្តាំ)។

បម្រែបម្រួលទឹកភ្លៀង (មម) ដែលព្យាករណ៍សម្រាប់រយៈពេល
៧ថ្ងៃ ចាប់ពីថ្ងៃទី ១៦-២២ ខែកុម្ភៈ ឆ្នាំ២០២២




Source:
MOWRAM - http://www.cambodiameteo.com/
NOAA, Climate Prediction Center - https://www.cpc.ncep.noaa.gov/products/Global_Monsoons/Asian_Monsoons/gfs_model.shtml

# ការព្យាករណ៍សម្រាប់រដូវកាល

ទិន្នន័យព្យាករណ៍សម្រាប់រដូវកាលរបស់គណៈកម្មការទន្លេមេគង្គ (MRC) និង សេចក្ដីជូនដឹងរបស់ក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី០២ ខែកុម្ភៈ បានបង្ហាញថា រយៈពេល ៣ខែខាងមុខ (ខែកុម្ភៈ ខែមិនា និងខែមេសា) ប្រទេសកម្ពុជា នឹងអាចទទួលទឹកភ្លៀងក្នុងកម្រិតចាប់ពីធម្មតារហូតដល់ច្រើនជាងមធ្យមភាគច្រើនឆ្នាំ។ ចាប់ពីតំបន់ភាគខាងត្បូងរហូតដល់តំបន់ភាគខាងជើងឈៀងខាងកើតនៃប្រទេស នឹងទទួលទឹកភ្លៀងក្នុងកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ (ផែនទីខាងក្រោម)។ រដូវវស្សាឆ្នាំ២០២២ អាចនឹងចាប់ផ្ដើមនៅសប្ដាហ៍ទី១ នៃខែឧសភា នៅតំបន់វាលទំនាប និងតំបន់មាត់សមុទ្រ ហើយនៅសប្ដាហ៍ទី២ នៅតំបន់ខ្ពង់រាប។

បម្រែបម្រួលទឹកភ្លៀងមធ្យមភាគប្រចាំថ្ងៃដែលព្យាករណ៍សម្រាប់ខែកុម្ភៈ ខែមិនា ខែមេសា ឆ្នាំ២០២២

ខែកុម្ភៈ ខែមិនា ខែមេសា




Source: MRC and MOWRAM - http://www.cambodiameteo.com/

# សូមអរគុណ

ព័ត៌មានលម្អិត៖

**Benjamin Scholz** - benjamin.scholz@wfp.org

**Yav Long** - yav.long@wfp.org

**Chanvibol Choeur** - chanvibol.choeur@wfp.org

**Vannareth** - Huoy vannareth.huoy@wfp.org